# ការរៀនសូត្រក្នុងបព្វជិតភាព

ប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

*បើអ្នកឧស្សាហ៍ហើយមានការប្រតិបត្តិក្នុងបព្វជិតភាព នោះទ្រព្យសម្បត្តិនៃចំណេះដឹងខាងវិញ្ញាណនឹងចាក់ស្រោចមកលើអ្នក ។*

ខ្ញុំមានអំណរគុណដោយបាននៅជាមួយអ្នកក្នុងការប្រជុំនៃបព្វជិតភាពនៃជុំវិញពិភពលោក ។ នារាត្រីនេះ យើងស្ថិតនៅកន្លែងផ្សេងៗពីគ្នា និងក្នុងកម្រិតជាច្រើននៃការបម្រើបព្វជិតភាពរបស់យើង ។ តែ រួមនឹងរាល់ស្ថានភាពផ្សេងគ្នារបស់យើងនេះ យើងមានតម្រូវការមួយដូចគ្នា ។ វាគឺជាការរៀនពីភារកិច្ចរបស់យើងក្នុងបព្វជិតភាព និងការរីកចម្រើនក្នុងអំណាចរបស់យើងដើម្បីអនុវត្តភារកិច្ចទាំងនោះ ។

កាលពីនៅជាឌីកុន ខ្ញុំត្រូវការវាយ៉ាងខ្លាំង ។ ខ្ញុំបានរស់នៅក្នុងសាខាតូចមួយនៅរដ្ឋ នូជេស៊ី គឺនៅភាគខាងកើតនៃសហរដ្ឋអាមេរិក ។ ខ្ញុំគឺជាឌីកុនតែម្នាក់គត់ក្នុងសាខានោះ ។ បងប្រុសខ្ញុំគឺជាគ្រូតែម្នាក់គត់ ។ ពេលខ្ញុំរស់នៅទីនោះ គឺគ្មានសង្ឃណាម្នាក់នៅក្នុងសាខារបស់យើងឡើយ ។

ពេលខ្ញុំនៅជាឌីកុន គ្រួសារខ្ញុំបានផ្លាស់ទីរដ្ឋយូថាហ៍ ។ នៅទីនោះ ខ្ញុំបានឃើញរឿងល្អបីយ៉ាងដើម្បីពន្លឿនដល់ការរីកចម្រើនរបស់ខ្ញុំក្នុងបព្វជិតភាព ។ រឿងទីមួយ គឺការមានប្រធានម្នាក់ដែលដឹងពីរបៀបអង្គុយក្នុងក្រុមប្រឹក្សាជាមួយនឹងសមាជិកកូរ៉ុមខ្លួន ។ រឿងទីពីរ គឺជាក្ដីជំនឿដ៏មុតមាំលើព្រះយេស៊ូវគ្រីស្ទដែលនាំទៅរកក្ដីស្រឡាញ់ដ៏ធំធេងចំពោះគ្នានឹងគ្នា ។ ហើយរឿងទីបី គឺការចែកចាយការប្រែចិត្តជឿមួយថា គោលបំណងនៃបព្វជិតភាពរបស់យើងគឺដើម្បីធ្វើការងារសម្រាប់សេចក្ដីសង្គ្រោះដល់មនុស្ស ។

វាមិនមែនជារួដដែលមានការរៀបចំយ៉ាងល្អដែលធ្វើឲ្យការណ៍នេះកើតឡើងឡើយ ។ អ្វីដែលកើតមាននៅទីនោះអាចកើតមានគ្រប់ទីកន្លែង វាអាចកើតឡើងនៅក្នុងអង្គភាពសាសនាចក្រណាមួយដែលអ្នកចូលរួមក៏អាចថាបាន ។

រឿងបីយ៉ាងនេះ អាចកើតមានក្នុងកូរ៉ុមបព្វជិតភាពរបស់អ្នកក៏ថាបាន គ្រាន់តែអ្នកពិបាកនឹងមើលឃើញវាប៉ុណ្ណោះ ។ ចំពោះអ្នកផ្សេងទៀត អ្នកអាចនឹងមិនត្រូវការការរីកចម្រើនក៏ថាបាន ដូច្នេះជំនួយទាំងនេះគឺប្រហែលជានឹងមិនចាំបាច់ចំពោះអ្នកឡើយ ។ ប៉ុន្តែ ខ្ញុំសូមអធិស្ឋានថា ព្រះវិញ្ញាណនឹងជួយខ្ញុំឲ្យបញ្ជាក់វាឲ្យច្បាស់ និងមានភាពទាក់ទាញដល់អ្នក ។

គោលបំណងរបស់ខ្ញុំក្នុងការលើកឡើងពីជំនួយទាំងបីដើម្បីរីកចម្រើនក្នុងបព្វជិតភាព គឺដើម្បីជំរុញអ្នកនៅក្នុងការរៀនឲ្យតម្លៃវា ហើយប្រើប្រាស់វា ។ បើអ្នកធ្វើដូច្នេះ ការបម្រើរបស់អ្នកនឹងមានភាពប្រសើរឡើង ។ ហើយបើវាត្រូវបានលើកតម្កើង នោះការបម្រើរបស់អ្នកក្នុងបព្វជិតភាពនឹងប្រទានពរដល់កូនចៅរបស់ព្រះវរបិតាសួគ៌លើសពីអ្វីដែលអ្នកស្រមៃថាអាចធ្វើបាននៅពេលនេះទៅទៀត ។

ខ្ញុំបានរកឃើញនូវចំណុចទីមួយ ពេលខ្ញុំត្រូវបានទទួលស្វាគមន៍ឲ្យចូលក្នុងកូរ៉ុមសង្ឃមួយជាមួយនឹងប៊ីស្សព ដែលជាប្រធានរបស់យើង ។ នោះប្រហែលជារឿងតូចតាចសម្រាប់អ្នក តែវាធ្វើឲ្យខ្ញុំមានអារម្មណ៍មួយនៃអំណាចក្នុងបព្វជិតភាពដែលបានផ្លាស់ប្ដូរការបម្រើរបស់ខ្ញុំក្នុងបព្វជិតភាពតាំងពីពេលនោះមក ។ វាបានផ្ដើមតាមរបៀបដែលគាត់បានដឹកនាំយើង ។

តាមខ្ញុំគិត គាត់បានឲ្យតម្លៃទៅលើគំនិតរបស់ពួកសង្ឃវ័យក្មេង ប្រៀបដូចយើងជាអ្នកដែលឈ្លាសវៃបំផុតក្នុងពិភពលោក ។ គាត់ចាំរហូតដល់អ្នកដែលត្រូវនិយាយបាននិយាយអស់ ។ គាត់បានស្ដាប់ ។ ហើយពេលគាត់សម្រេចថាត្រូវធ្វើអ្វីនោះ ចំពោះខ្ញុំវាហាក់ដូចជាព្រះវិញ្ញាណបានបញ្ជាក់ពីការសម្រេចចិត្តនោះដល់យើង និងគាត់ ។

ឥឡូវនេះខ្ញុំដឹងថា ខ្ញុំបានយល់ពីអ្វីដែលព្រះគម្ពីរចង់មានន័យ ពេលចែងថា ប្រធានគឺត្រូវអង្គុយក្នុងក្រុមប្រឹក្សាជាមួយនឹងសមាជិកនៃកូរ៉ុមរបស់គាត់ ។[1] ហើយច្រើនឆ្នាំក្រោយមក ពេលខ្ញុំក្លាយជាប៊ីស្សពចូលរួមក្នុងកូរ៉ុមសង្ឃរបស់ខ្ញុំ ទាំងពួកគេទាំងខ្ញុំត្រូវបានបង្រៀននូវអ្វីដែលខ្ញុំបានរៀនកាលពីនៅជាសង្ឃ ។

ម្ភៃឆ្នាំក្រោយមក ក្នុងនាមជាប៊ីស្សព ខ្ញុំមានឱកាសមើលឃើញពីប្រសិទ្ធភាពនៃក្រុមប្រឹក្សា មិនមែនតែក្នុងសាលាប្រជុំប៉ុណ្ណោះទេ តែនៅលើភ្នំ ។ ក្នុងសកម្មភាពមួយនាថ្ងៃសៅរ៍ មានសមាជិកម្នាក់ក្នុងកូរ៉ុមយើងបានវង្វេងបាត់ក្នុងព្រៃនាពេលយប់ ។ តាមខ្ញុំដឹង គាត់បាននៅតែឯង ហើយគ្មានអាវរងា គ្មានអាហារ ឬទឹកជម្រកឡើយ ។ យើងបានដើររកគាត់មិនឃើញសោះ ។

ខ្ញុំនៅចាំថា យើងបានអធិស្ឋានរួមគ្នា រួចហើយក៏បានពិភាក្សាគ្នា ។ ខ្ញុំបានស្ដាប់ដោយយកចិត្តទុកដាក់ ហើយខ្ញុំគិតថាគេក៏បានធ្វើដូច្នេះដែរ ។ លុះមួយសន្ទុះមក មានអារម្មណ៍នៃក្ដីសុខសាន្តមួយបានគ្របដណ្ដប់មកលើយើង ។ ខ្ញុំយល់ថា សមាជិកកូរ៉ុមយើងដែលវង្វេងនោះមានសុវត្ថិភាព នៅកន្លែងណាមួយជាពុំខានឡើយ ។

ខ្ញុំបានយល់យ៉ាងច្បាស់ពីអ្វីដែលកូរ៉ុមត្រូវធ្វើ ។ ពេលមនុស្សដែលរកគាត់ឃើញបានរៀបរាប់ពីទីកន្លែងក្នុងព្រៃដែលគាត់បានទីជ្រក ខ្ញុំយល់ថាខ្ញុំស្គាល់កន្លែងនោះ ។ អព្ភូតហេតុចំពោះខ្ញុំគឺការឃើញពីអំណាចនៃក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទនៃក្រុមប្រឹក្សាបព្វជិតភាពមួយដែលរួមគ្នា បាននាំ
វិវរណៈមកឲ្យបុរសម្នាក់ដែលមានកូនសោបព្វជិតភាព ។ យើងទាំងអស់គ្នាបានរីកចម្រើនក្នុងអំណាចនៃបព្វជិតភាពនៅថ្ងៃនោះ ។

គន្លឹះទីពីរដើម្បីពន្លឿនការរៀនសូត្រគឺការស្រឡាញ់ចំពោះគ្នានឹងគ្នាដែលកើតចេញពីក្ដីជំនឿដ៏រឹងមាំ ។ ខ្ញុំមិនប្រាកដថាកត្តាមួយណាកើតមុននោះទេ តែកត្តាទាំងពីរតែងតែកើតមានពេលណាមានការរៀនសូត្រដ៏អស្ចារ្យហើយរហ័សក្នុងបព្វជិតភាព ។ លោក យ៉ូសែប ស្ម៊ីធ បានបង្រៀនការណ៍នោះដល់យើងតាមរយៈគំរូរបស់លោក ។
ក្នុងសម័យដើមនៃសាសនាចក្រនាគ្រាកាន់កាប់នេះ លោកបានទទួលបញ្ញាមួយពីព្រះដើម្បីពង្រឹងកម្លាំងក្នុងបព្វជិតភាព ។ លោកត្រូវបង្កើតសាលារៀនសម្រាប់អ្នកកាន់បព្វជិតភាព ។ ព្រះអម្ចាស់បានដាក់លក្ខខណ្ឌថាអ្នកដែលរៀន និងអ្នកដែលបង្រៀនត្រូវមានក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ។ នេះគឺជាបន្ទូលរបស់ព្រះអម្ចាស់ពីការបង្កើតទីកន្លែងមួយនៃការរៀនពីបព្វជិតភាព និងអ្វីដែលស្រដៀងគ្នានេះចំពោះអ្នកដែលត្រូវរៀននៅក្នុងនោះ ៖

« ចូររៀបចំខ្លួន … ចូរតាំងគេហដ្ឋាន…នៃការរៀនសូត្រ គេហដ្ឋាននៃរបៀបរៀបរយ … ។ ចូរតាំងគ្រូបង្រៀនម្នាក់ក្នុងចំណោមអ្នករាល់គ្នា ហើយចូរកុំឲ្យទាំងអស់គ្នានិយាយព្រមគ្នាឡើយ ប៉ុន្តែចូរឲ្យនិយាយម្នាក់ម្ដង ហើយចូរឲ្យទាំងអស់គ្នាស្ដាប់ពាក្យសំដីរបស់អ្នកនោះ ប្រយោជន៍កាលណាទាំងអស់គ្នានិយាយនោះទើបឲ្យទាំងអស់បានស្អាងឡើងទាំងអស់គ្នា ហើយប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចបានសិទ្ធិស្មើគ្នា » ។[2]

ព្រះអម្ចាស់កំពុងរៀបរាប់ពីអ្វីដែលយើងធ្លាប់ឃើញរួចហើយ គឺជាកម្លាំងនៃក្រុមប្រឹក្សា ឬថ្នាក់បព្វជិតភាពមួយដើម្បីនាំវិវរណៈដោយព្រះវិញ្ញាណ ។
វិវរណៈគឺជារបៀបតែមួយគត់ដែលយើងអាចដឹងថា ព្រះយេស៊ូវគឺជាព្រះ -គ្រីស្ទ ។ ក្ដីជំនឿគឺជាកាំជណ្ដើរទីមួយដែលយើងឡើងដើម្បីរៀនពីគោលការណ៍នៃដំណឹងល្អ ។

ក្នុងកណ្ឌទី 88 នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ខទី 123 និង 124 ព្រះអម្ចាស់បានគូសបញ្ជាក់ពីក្ដីស្រឡាញ់ និងការមិនស្វែងរកកំហុស ចំពោះគ្នានឹងគ្នា ។ បព្វជិតភាពម្នាក់ៗអាចចូលរៀនក្នុងសាលាបព្វជិតភាពដែលបង្កើតឡើងដោយព្រះអម្ចាស់ ដោយការលើកដៃសច្ចាដើម្បីធ្វើជា « មិត្តនិងជាបងប្អូន …ក្នុងចំណងនៃសេចក្ដីស្រឡាញ់ » ។[3]

សព្វថ្ងៃ យើងមិនបានធ្វើតាមការអនុវត្តន៍នោះឡើយ តែពេលណាខ្ញុំបានឃើញពីការរៀនសូត្រដ៏អស្ចារ្យក្នុងបព្វជិតភាព គឺមានចំណងនៃក្ដីស្រឡាញ់ទាំងនោះ ។ ជាថ្មីម្ដងទៀត ខ្ញុំបានឃើញវាដោយសារបុព្វហេតុនិងប្រសិទ្ធភាពនៃការរៀនពីសេចក្ដីពិតនៃដំណឹងល្អ ។ ក្ដីស្រឡាញ់អញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យយាងមកបញ្ជាក់ពីសេចក្ដីពិត ។ហើយក្ដីអំណរនៃការរៀនពីសេចក្ដីពិតដ៏ទេវភាពបង្កើតជាក្ដីស្រឡាញ់ក្នុងដួងចិត្តនៃមនុស្សដែលចែកចាយបទពិសោធន៍នៃការរៀនសូត្រនោះ ។

ហើយបញ្ច្រាសមកវិញក៏ពិតផងដែរ ។ ការទាស់ទែងគ្នា ឬការច្រណែនកាត់បន្ថយនូវសមត្ថភាពនៃព្រះវិញ្ញាណដើម្បីបង្រៀនយើង និងសម្រាប់យើងដើម្បីទទួលបានពន្លឺនិងសេចក្ដីពិត ។ ហើយក្នុងអារម្មណ៍នៃការខកបំណងដែលតែងតែកើតឡើង គឺជាគ្រាប់ពូជនៃការមិនចុះសម្រុង និងការស្វែងរកកំហុសគ្នាដ៏ធំក្នុងចំណោមអ្នកដែលបានរំពឹងទុកនូវបទពិសោធន៍នៃការរៀនសូត្រមួយដែលគេមិនបានទទួល ។

ពួកអ្នកកាន់បព្វជិតភាពដែលរួមគ្នារៀនបានយ៉ាងល្អ ខ្ញុំតែងតែឃើញមានពួកអ្នកផ្សះផ្សាជាច្រើនក្នុងចំណោមពួកគេ ។ អ្នកឃើញវាក្នុងថ្នាក់បព្វជិតភាព និងក្នុងក្រុមប្រឹក្សា ។ វាគឺជាអំណោយទានដើម្បីជួយមនុស្សឲ្យស្គាល់នូវអ្វីដូចគ្នាដែលគេមាន ពេលគេកំពុងមើលឃើញពីភាពខុសគ្នា ។ វាគឺជាអំណោយទានដើម្បីជួយមនុស្សឲ្យមើលឃើញអ្វីដែលមនុស្សម្នាក់បានលើកឡើងគឺជាការផ្ដល់យោបល់ ជាជាងការកែតម្រូវ ។

ដោយមានក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទល្មមគ្រប់គ្រាន់ និងក្ដីប្រាថ្នាមួយដើម្បីធ្វើជាអ្នកផ្សះផ្សា នោះសាមគ្គីភាពនឹងកើតមានក្នុងក្រុមប្រឹក្សានិងក្នុងថ្នាក់ទាំងឡាយ ។ វាតម្រូវឲ្យមានការអត់ធ្មត់ និងចិត្តសប្បុរស តែខ្ញុំក៏ធ្លាប់ឃើញវាកើតឡើងទាំងនៅពេលដែលបញ្ហាមានភាពតានតឹង ហើយមនុស្សក្នុងក្រុមប្រឹក្សានិងក្នុងថ្នាក់មានទស្សនៈផ្សេងៗគ្នាផងដែរ ។

ការសម្រេចនូវបទដ្ឋានដ៏ខ្ពស់ដែលព្រះអម្ចាស់បានដាក់សម្រាប់អ្នកកាន់បព្វជិតភាពក្នុងការធ្វើការសម្រេចចិត្តក្នុងកូរ៉ុមអាចធ្វើទៅបាន ។ វាអាចកើតឡើងបាន ពេលមានក្ដីជំនឿ និងក្ដីស្រឡាញ់ដ៏ធំ និងអវត្តមាននៃការទាស់ទែងគ្នា ។

« ហើយការសម្រេចចិត្តណាមួយដែលបានធ្វើឡើងដោយក្រុមទាំងនេះត្រូវបានធ្វើឡើង ដោយសម្លេងនៃក្រុមទាំងនោះជាឯកច្ឆន្ទ គឺថាសមាជិកគ្រប់រូបនៅក្នុងក្រុមនីមួយៗត្រូវយល់ព្រមនឹងការសម្រេចចិត្តទាំងឡាយនៃក្រុមរបស់ខ្លួន ដើម្បីធ្វើការសម្រេចចិត្តទាំងឡាយរបស់ពួកគេ ដោយមានអំណាច ឬសុពលភាពនិងគ្នាទៅវិញទៅមក ។[4]

ជំនួយទីបីចំពោះការរៀនសូត្រក្នុងបព្វជិតភាពកើតឡើងជាមួយនឹងការចែកចាយនៃការប្រែចិត្តជឿពីហេតុផលដែលព្រះអម្ចាស់ប្រទានពរនិងទុកព្រះទ័យលើយើង ឲ្យកាន់ និងអនុវត្តបព្វជិតភាពរបស់ទ្រង់ ។ វាគឺជាការធ្វើការសម្រាប់ការសង្គ្រោះដល់មនុស្សលោក ។ ការចែកចាយនៃការប្រែចិត្តជឿនៃនាំមកនូវសាមគ្គីភាពក្នុងកូរ៉ុម ។ យើងអាចផ្ដើមរៀនពីការណ៍នេះក្នុងដំណើររឿងនៃព្រះគម្ពីរពីរបៀបដែលយើងជាបុត្រាខាងវិញ្ញាណត្រូវបានរៀបចំពីមុនការចាប់កំណើតសម្រាប់កិត្តិយសដ៏កម្រនៃការកាន់បព្វជិតភាពនោះ ។

ដោយនិយាយទៅអ្នកដែលបានទទួលបព្វជិតភាពដ៏អស្ចារ្យក្នុងជីវិតនេះ នោះទ្រង់បានមានបន្ទូលថា ៖

« ចាប់តាំងពីមុនកំណើត នោះពួកគេជាមួយនឹងពួកអ្នកផ្សេងទៀត បានទទួលមេរៀនមុនដំបូងនានា នៅលើពិភពនៃពួកវិញ្ញាណ ហើយត្រូវបានរៀបចំឲ្យមក នៅពេលកំណត់នៃព្រះ ដើម្បីធ្វើការងារនៅក្នុងចម្ការទំពាំងបាយជូររបស់ទ្រង់ សម្រាប់សេចក្ដីសង្គ្រោះដល់មនុស្សលោក » ។[5]
ក្នុងបព្វជិតភាព យើងចែករំលែកភារកិច្ចដ៏ពិសិដ្ឋដើម្បីធ្វើការសម្រាប់ការសង្គ្រោះដល់ព្រលឹងមនុស្សលោក ។ យើងត្រូវធ្វើឲ្យបានច្រើនជាងអ្វីដែលយើងដឹងថាជាភារកិច្ចរបស់យើង ។ យើងត្រូវតែយល់ពីភារកិច្ចនោះឲ្យបានច្រើនរហូតដល់តម្រូវការជាច្រើនរបស់យើងក្នុងយុវវ័យ ឬការសោកល្បងដែលកើតឡើងដោយអាយុមិនអាចបង្វែរយើងចេញពីគោលបំណងនោះបានឡើយ ។

ថ្មីៗនេះ ខ្ញុំបានទៅសួរសុខទុក្ខសង្ឃជាន់ខ្ពស់ម្នាក់នៅផ្ទះគាត់ ។ គាត់មិនអាចចូលរួមក្នុងការប្រជុំកូរ៉ុមរបស់យើងបានទៀតឡើយ ។ គាត់រស់នៅតែឯង ។ ភរិយាដ៏ស្រស់ស្អាតរបស់គាត់បានស្លាប់ ហើយកូនចៅគាត់រស់នៅឆ្ងាយពីគាត់ ។ ពេលវេលានិងជំងឺបានកំណត់សមត្ថភាពនៃការបម្រើរបស់គាត់ ។ គាត់នៅបន្តលើកដុំដែកដើម្បីជួយឲ្យគាត់អាចមានកម្លាំងរឹងមាំ ។

ពេលខ្ញុំបានដើរចូលក្នុងផ្ទះគាត់ គាត់បានក្រោកឡើងនឹងឈើច្រត់គាត់មករាក់ទាក់នឹងខ្ញុំ ។ គាត់បានអញ្ជើញខ្ញុំឲ្យអង្គុយនៅកៅអីមួយក្បែរគាត់ ។ យើងបាននិយាយពីទំនាក់ទំនងដ៏រីករាយរបស់យើងក្នុងបព្វជិតភាព ។

រួច ដោយមានកម្លាំងរឹងមាំ គាត់បាននិយាយមកខ្ញុំថា ៖ « ហេតុអ្វីខ្ញុំនៅមានជីវិត ? ហេតុអ្វីខ្ញុំនៅទីនេះទៀត ? ខ្ញុំមិនអាចធ្វើអ្វីបានឡើយ ។

ខ្ញុំបានប្រាប់គាត់ថា គាត់កំពុងធ្វើរឿងមួយដល់ខ្ញុំ ។ គាត់កំពុងពង្រឹងខ្ញុំជាមួយនឹងក្តីជំនឿនិងក្តីស្រឡាញ់របស់គាត់ ។ ទោះជាយើងជួបគ្នាក្នុងពេលដ៏ខ្លីក្តី ក៏គាត់បានធ្វើឲ្យខ្ញុំចង់ក្លាយជាមនុស្សម្នាក់ដែលប្រសើរដែរ ។  គំរូរបស់គាត់ពីការតាំងចិត្តធ្វើអ្វីមួយដែលសំខាន់បានបំផុសគំនិតខ្ញុំឲ្យព្យាយាមថែមទៀតក្នុងការបម្រើដល់អ្នកដទៃនិងព្រះអម្ចាស់ ។

នៅក្នុងសូរសៀងដ៏សោកសៅនៃសម្លេងគាត់ និងកែវភ្នែកគាត់ ខ្ញុំអាចដឹងថា ខ្ញុំមិនបានឆ្លើយនឹងសំណួររបស់គាត់ឡើយ ។ គាត់នៅឆ្ងល់ថាហេតុអ្វីបានជាព្រះឲ្យគាត់នៅមានជីវិតជាមួយនឹងសមត្ថភាពរបស់គាត់ក្នុងការបម្រើដ៏មានកំណត់បែបនេះទៅវិញ ។

តាមវិធីសប្បុរសរបស់គាត់ជាធម្មតា  គាត់បានអរគុណខ្ញុំដែលបានមកមើលគាត់ ។  ពេលខ្ញុំក្រោកឡើងដើរចេញ  នោះគ្រូពេទ្យដែលមកផ្ទះគាត់ពីរទៅបីម៉ោងរៀងរាល់ថ្ងៃបានដើរចេញពីបន្ទប់មួយទៀត ។ ក្នុងការសន្ទនារបស់យើងតែពីរនាក់ គាត់បានប្រាប់ខ្ញុំខ្លះដែរពីនាង ។ នាងបានរស់នៅក្នុងចំណោមពួកបរិសុទ្ធថ្ងៃចុងក្រោយស្ទើរតែមួយជីវិតនាង តែនាងនៅតែមិនទាន់ក្លាយជាសមាជិកនៅឡើយ ។

នាងបានដើរបើកទ្វារឲ្យខ្ញុំ ។  គាត់បាននិយាយទៅនាងទាំងញញឹមថា  « ឃើញទេ  ខ្ញុំមិនអាចធ្វើអ្វីបានឡើយ ។  ខ្ញុំធ្លាប់ព្យាយាមប្រាប់នាងឲ្យជ្រមុជទឹក ហើយក្លាយជាសមាជិក តែវាពុំបានការឡើយ » ។ នាងបានញញឹមដាក់គាត់ ហើយនិងខ្ញុំ ។ ខ្ញុំបានដើរចេញទៅក្រៅ ហើយបានដើរតម្រង់ទៅផ្ទះខ្ញុំ ។

រួចខ្ញុំបានដឹងថា ចម្លើយសម្រាប់សំណួររបស់គាត់បានកើតមានក្នុងដួងចិត្តគាត់ជាយូរមកហើយ ។ សង្ឃជាន់ខ្ពស់ដ៏អង់អាចម្នាក់នេះកំពុងព្យាយាមបំពេញភារកិច្ចរបស់គាត់ ដែលបានបង្រៀនដល់គាត់តាមរយៈពេលវេលាជាច្រើនឆ្នាំរបស់គាត់ក្នុងបព្វជិតភាព ។

គាត់បានដឹងថា មានតែវិធីមួយគត់ដែលយុវនារីម្នាក់អាចទទួលពរជ័យនៃការសង្គ្រោះតាមរយៈដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺការចុះសេចក្តីសញ្ញាដោយការជ្រមុជទឹក ។ គាត់បានទទួលការបង្រៀនស្របតាមសេចក្តីសញ្ញាមកពីគ្រប់ប្រធាននៃវាល់កូរ៉ុម តាំងពីឌីកុនរហូតដល់សង្ឃជាន់ខ្ពស់ ។

គាត់បានចាំហើយយល់ពីសម្បថនិងសេចក្តីសញ្ញាបព្វជិតភាពរបស់គាត់ ។ គាត់កំពុងតែរក្សាវា ។

គាត់ជាសាក្សី  និងជាអ្នកផ្សព្វផ្សាយសាសនាម្នាក់សម្រាប់ព្រះអង្គសង្គ្រោះ  នៅគ្រប់ស្ថានភាព ។ វាស្ថិតក្នុងដួងចិត្តគាត់រួចជាស្រេចហើយ ។  ក្តីប្រាថ្នាក្នុងដួងចិត្តគាត់គឺថា ដួងចិត្តនាងអាចផ្លាស់ប្តូរតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងដោយការរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋនានា ។

ពេលវេលារបស់គាត់ក្នុងសាលានៃបព្វជិតភាពនៅជីវិតនេះ គឺខ្លីបើប្រៀបធៀបនឹងភាពអស់កល្បនោះ ។ តែទោះជាស្ថិតក្នុងពេលដ៏ខ្លីនេះក្តី ក៏គាត់បានរៀនយ៉ាងស្ទាត់ជំនាញពីមេរៀនដ៏អស់កល្បដែរ ។ គាត់នឹងនាំទៅជាមួយគាត់នូវមេរៀនបព្វជិតភាពដែលមានតម្លៃអស់កល្ប ពេលណាព្រះអម្ចាស់នឹងហៅគាត់ ។

អ្នកត្រូវមានបំណងដើម្បីរៀនពីមេរៀនបព្វជិតភាពរបស់អ្នក  និងត្រូវមានភាពសុទិដ្ឋិនិយមចំពោះអ្វីដែលអាចកើតមាន ។  មានយើងមួយចំនួនប្រហែលជាកំណត់នៅក្នុងគំនិតនូវឱកាសរបស់យើងដើម្បីរៀនពីអ្វីដែលព្រះអម្ចាស់បានប្រទានឲ្យយើងនៅក្នុងការបម្រើរបស់ទ្រង់ ។

មានយុវជនម្នាក់បានចាកចេញពីភូមិដ៏តូចរបស់ខ្លួនឈ្មោះ វ៉េលស៍ ដោយបានឮពីពួកសាវកនៃព្រះ ហើយបានចូលមកក្នុងនគរព្រះលើផែនដី ។ គាត់បានជិះទូកជាមួយនឹងពួកបរិសុទ្ធទៅប្រទេសអាមេរិក ហើយបានជិះរទេះគោឆ្លងកាត់ទីវាលឆ្ពោះទៅភាគខាងលិច ។ ការបម្រើនៃបព្វជិតភាពរបស់គាត់ បានរួមបញ្ចូលទាំងការភ្ជួររាស់ដីផងដែរ ។

គាត់បានលក់ដីកសិដ្ឋានក្នុងតម្លៃថោកបំផុត ដើម្បីចេញបេសកកម្មបម្រើព្រះអម្ចាស់នៅតំបន់វាលខ្សាច់ ក្នុងការមើលថែដល់សត្វចៀម ។ គាត់ត្រូវបានហៅចេញពីនោះឲ្យបម្រើបេសកកម្មមួយឆ្លងកាត់មហាសមុទ្រក្នុងភូមិដែលគាត់បានចាកចេញដើម្បីដើរតាមព្រះអម្ចាស់ ។

នៅទីបំផុត គាត់បានរកឃើញវិធីមួយដើម្បីរៀនជាមួយនឹងបងប្អូនប្រុសនៃបព្វជិតភាព ។ ដោយសារគាត់ជាអ្នកផ្សព្វផ្សាយសាសនាដ៏អង់អាច នោះគាត់បានដើរចូលក្នុងបំបែកផ្លូវក្នុងប្រទេសវ៉េល ទៅកាន់ផ្ទះដ៏ធំនៃបុរសម្នាក់ដែលក្លាយជានាយករដ្ឋមន្ត្រីនៃប្រទេសអង់គ្លេសចំនួនបួនលើក ដើម្បីផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដល់បុរសនោះ ។

បុរសនោះបានឲ្យគាត់ចូលក្នុងវិមានខ្លួន ។ បុរសនោះបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យអេធិន និងអក់ស្វត ។ អ្នកផ្សព្វផ្សាយសាសនាម្នាក់នេះបាននិយាយជាមួយគាត់ពីដើមកំណើតរបស់មនុស្ស ដែលជាតួនាទីដ៏សំខាន់របស់ព្រះយេស៊ូវគ្រីស្ទក្នុងប្រវត្តិសាស្ត្រពិភពលោក រួមនឹងជោគវាសនានៃជាតិសាសន៍នានាផងដែរ ។

នៅចុងបញ្ចប់នៃជំនួបរបស់គេ បុរសនោះបានបដិសេធចំពោះការអញ្ជើញឲ្យទទួលបុណ្យជ្រមុជទឹក ។ តែពេលពួកគេបែកចេញពីគ្នា អ្នកដឹកនាំនៃអាណាចក្រដ៏ធំមួយនៃពិភពលោកបានសួរទៅអ្នកផ្សព្វផ្សាយដ៏រាបសានោះថា ៖ « តើអ្នកបានចំណេះដឹងនេះមកពីណា ? » ចម្លើយរបស់គាត់គឺ ៖ « នៅក្នុងបព្វជិតភាពនៃព្រះ » ។

អ្នកអាចគិតថា ជីវិតរបស់អ្នកនឹងប្រសើរឡើងដល់កម្រិតណាទៅ បើអ្នកបានតាំងចិត្តសិក្សាក្នុងសាលាតែម្តងនោះ ។ ខ្ញុំសូមអធិស្ឋានថា អ្នកនឹងមើលឃើញពីភាពអស្ចារ្យនៃក្តីស្រឡាញ់របស់ព្រះចំពោះអ្នក និងនៃឱកាសដែលទ្រង់បានប្រទានឲ្យអ្នកដើម្បីចូលក្នុងសាលារបស់ទ្រង់ ។

បើអ្នកឧស្សាហ៍ហើយមានការប្រតិបត្តិក្នុងបព្វជិតភាព នោះទ្រព្យសម្បត្តិនៃចំណេះដឹងខាងវិញ្ញាណនឹងចាក់ស្រោចមកលើអ្នក ។ អ្នកនឹងរីកចម្រើនក្នុងអំណាចរបស់អ្នកដើម្បីតតាំងនឹងអំពើអាក្រក់ និងដើម្បីប្រកាសសេចក្តីពិតដែលនាំទៅរកការសង្គ្រោះ ។ អ្នកនឹងរកឃើញក្តីអំណរក្នុងសុភមង្គលនៃអ្នកដែលអ្នកនាំទៅរកភាពតម្កើងឡើង ។ គ្រួសារអ្នកនឹងក្លាយជាកន្លែងនៃការរៀនសូត្រមួយ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា កូនសោបព្វជិតភាពត្រូវបានស្តារឡើងវិញ ។ ប្រធាន ថូម៉ាស អេស ម៉នសុន កាន់ និងមានសិទ្ធិប្រើកូនសោទាំងនោះ ។ ព្រះមានព្រះជន្មរស់ ហើយទ្រង់ស្គាល់អ្នកយ៉ាងច្បាស់ ។ អ្នកត្រូវបានរើសសម្រាប់កិត្តិយសនៃការកាន់បព្វជិតភាពនេះ ។ ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ។ ក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល គ. និង ស. 107:85 ។
2. គ. និង ស. 88:119, 122 ។
3. សូមមើល គ. និង ស. 88:133 ។
4. គ. និង ស. 107:27 ។
5. គ. និង ស.138:56 ។